**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២៣៣
ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៨

**សាលដីកា**
លេខ:២៣៤
ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម............. ជាប្រធាន
២-លោក ................ ជាចៅក្រមរបាយការណ៍
៣-លោក ................ ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ................ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក .............

**<u>តំណាងមហាអយ្យការ</u>**

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំនះលើបណ្តឹងសាទុក្ខពីសាដីកាលេខ៣១៧ ចុះថ្ងៃទី២២-០៦-៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៧-០៥-៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះពប ភេទស្រីអាយុ៦៨ ឆ្នាំ ជាតិខ្មែរមុខរបរធ្វើស្រែ មានទីលំនៅភូមិក្រញូង ឃុំពោធិអង្រ្គង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះហល ភេទស្រីអាយុ៤៥ ឆ្នាំជាតិខ្មែរមុខរបរលក់ដូរ ធ្វើស្រែ មានទីលំនៅ ភូមិក្រញូង ឃុំពោធិអង្រ្គង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះហោ កៅ(ស) ម្តាយឈ្មោះអោ ដាវ (ស) ប្តីឈ្មោះពេជ្រ ដឹម ។

**<u>កម្មវត្ថុបណ្តឹង</u>** ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលេខ២៧២ ចុះថ្ងៃទី០៩-០៧-១៩៩៨ របស់មេធាវីឈ្មោះប៉ាង សុជាការពារប្រជាជន១៨គ្រួសារ ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បណីលេខ២៣៣ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៥-០៦-៩៥ របស់ដើមចោទឈ្មោះហល ប្តឹងសុំឱ្យចុងចម្លើយរុះរើផ្ទះចេញពីដីកម្មសិទ្ធិរបស់ខ្លួនដោយសំអាងហេតុថា កាលពីមុនឈ្មោះនេះ បានសង់ផ្ទះលើដី ចិញ្ចើមថ្នល់ជាតិលេខ៣ ដល់ពលរដ្ឋអំណាចរៀបចំថ្នល់បត់នៅឆ្នាំ១៩៩១ ឱ្យប្រជាជន១៨ គ្រួសារ រុះរើថយក្រោយមចម្ងាយ៣៥ម. ពីថ្នល់ជាតិ ស្រាប់តែថយទៅជាន់លើដីកម្មសិទ្ធិរបស់ខ្លួនដែលបានធ្វើពាក្យ សុំកាន់កាប់តាំងពីឆ្នាំ១៩៨៩ ហើយមានប័ណ្ណកម្មសិទ្ធិនៅឆ្នាំ១៩៩២ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីជាខេ០៤ ចុះថ្ងៃទី១០-១១ ខែមករា ឆ្នាំ១៩៩៦របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៥ ទុកជាត្រឹម ត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទទួលស្គាល់ប័ណ្ណសំគាល់កម្មសិទ្ធិ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩២ របស់ដើមចោទ ទុកជាត្រឹមត្រូវ ចាប់ពីថ្ងៃនេះតទៅ ។

៣- បដិសេធបណ្តឹងតប ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៥ និងលិខិតផ្សេងៗរបស់ចម្លើយចោលជាអសាបង់ដោយខុសធតិច្បាប់ ។

៤- ប្រគល់ដីកើតហេតុនេះឱ្យទៅដើមចោទគ្រប់គ្រងជាកម្មសិទ្ធិចាប់តាំងពីថ្ងៃនេះតទៅ តាមមាត្រា ៣ នៃច្បាប់ភូមិបាល ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ១០០ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២។

៥- ឱ្យចុងចម្លើយរុះរើផ្ទះចេញពីដីកើតហេតុនេះ ចាប់តាំងពីថ្ងៃនេះតទៅ បើមិនព្រមរុះរើចេញ ទេត្រូវបង់ប្រាក់ថ្លៃដីឱ្យទៅដើមចោទតាមតម្លៃដីនៅមូលដ្ឋាននោះ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី និងបើកផ្លូវឧទ្ធរណ៍តាមច្បាប់

៧-បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ក្នុងនោះមានប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធហ្នឹងចំនួន១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់ប្រគល់ដីកាកោះចំនួន៥០០០រៀល សរុបចំនួន៧០០០រៀល ដែលដើមចោទបានបង់រួចហើយ ហើយបង្គាប់ឲ្យចុងចម្លើយសងទៅដើមទៅវិញ និងបង់ពន្ធសមាមាត្រចំនួនមួយភាគយលើថ្លៃដី ។

បានឃើញសេចក្តីសុំប្តឹងតវ៉ាលេខ០៣ ចុះថ្ងៃទី១០-០១-៩៦ របស់ឈ្មោះពបប្តឹងមិនសុខចិត្តនឹងសេចក្តីនិច្ឆ័យរបស់តុលាការខេត្តកំពង់ស្ពឺទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលខ១៧ ចុះថ្ងៃទី២២-០៦-៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពេក្យសុំដកពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-០៨-១៩៩៧ របស់ឈ្មោះពបទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ចំណាយរឿងក្តីលេខ២១៤ ចុះថ្ងៃទី០៧-០៥-៩៧ របស់សាលាឧទ្ធរណ៍ចេញពីបញ្ជីក្តី ។

៣-សម្រេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ចំនួន១៣.០០០រៀល ដែលដើមបណ្តឹង ឧទ្ធរណ៍បានបង់រួចហើយតីពន្ធចុះបញ្ជីក្តី១២៧៥រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២២៥រៀល ចំណាយលើកកិច្ចប្រគល់ដីកាកោះ៥០០០រៀល និងលើអង្គាធរតុលាការ៥០០០រៀល ។

៤-សាលដីកានេះជំនុំជំនះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខ ចុងចម្លើយ ។ បើកផ្លូវ ប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៧២ ចុះថ្ងៃទី០៩-០៧-៩៨ របស់មេធាវីប៉ាង សុជា ការពារប្រជាជន១៨គ្រួសារ ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេច របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាយ្យការថា៖ លើកបណ្តឹងសាទុក្ខចោល អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ពាក្យសុំឈប់ប្តឹរបស់ឈ្មោះពប ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ពាក្យសុំឈប់ប្តឹងរបស់អ្នកស្រីពប និងចម្លើយបញ្ជាក់របស់អ្នកស្រីហល

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៧២ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៨ របស់លោកប៉ាង សុជា មេធាវីការពារប្រជាជន១៨គ្រួសារ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ។

-យល់ឃើញថា តាមពាក្យបណ្តឹងពុំមានចុះថ្ងៃ ខែមេសា ឆ្នាំ១៩៩៨ ឈ្មោះពប បានសុំដកបណ្តឹងឧទ្ធរណ៍របស់ខ្លួន នៅសាលាឧទ្ធរណ៍រួចហើយ ហើយការដែលលោកមេធាវី ប្តឹងសាទុក្ខ មកតុលាការកំពូលនេះ មិនស្របតាមឆន្ទះរបស់កូនក្តីលោកឡើយ ។

-យល់ឃើញថា អ្នកស្រីពប បានដាក់ពាក្យសុំដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនរួចហើយ ហើយអ្នកស្រីពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំរុំជំរះរឿងនេះ កំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីយខ៣១៧ ចុះថ្ងៃទី ២២-០៦-៩៨ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**
**វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកស្រីហាល កំចាំងមុខអ្នកស្រីពប**
**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-បដិសេធបណ្តឹងសាទុក្ខលេខ២៧២ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៨ របស់លោកមេធាវី ប៉ាង សុធា ចោលជាអសារបង់ ។

២-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ២៣៣ ចុះថ្ងៃទី២៥-០៨-៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការតាមច្បាប់ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០រៀល ដែលអ្នកស្រីពប បានបង់រួចហើយគឺៈ

-ពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវគាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៤-សាលដីកានេះ ប្រកាសនាសនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨ ។